ក

# មាតិកា

## I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៤-១២-២០១០ - ព្រះរាជក្រឹត្យ នស/រកត/១២១០/៩៦២ ស្តីពី ការប្រោសព្រះរាជទាន នូវ គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ លោក **យ៉ុំ សាខឹង** ៩៨៩៣

២៤-១២-២០១០ - ព្រះរាជក្រឹត្យ នស/រកត/១២១០/៩៦៣ ស្តីពី ការដំឡើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **ឌីម សារឿន** នាយនគរបាលជាតិ ជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៩៨៩៤

២៤-១២-២០១០ - ព្រះរាជក្រឹត្យ នស/រកត/១២១០/៩៦៤ ស្តីពី ការប្រោសព្រះរាជទានជាកិច្ចបច្ឆាមរណៈ នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះសពនាយទាហាន នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៨ រូប ៩៨៩៥

២៤-១២-២០១០ - ព្រះរាជក្រឹត្យ នស/រកត/១២១០/៩៦៥ ស្តីពី ការប្រោសព្រះរាជទាននូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ នាយនគរបាលជាតិ នាយទាហាន មន្ត្រីរាជការ និង សប្បុរសជន ចំនួន ២១ រូប ៩៨៩៦

២៧-១២-២០១០ - ព្រះរាជក្រឹត្យ នស/រកត/១២១០/៩៦៧ ស្តីពី ការតែងតាំង ឯកឧត្តម **តែ ណាវុធ** ជាអគ្គលេខាធិការគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ ជំនួសឯកឧត្តម **ពេជ ឌុន** ដែលត្រូវបានចាត់ឱ្យទទួលភារកិច្ចថ្មី ៩៨៩៨


## II. រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ


២៨-១២-២០១០ - អនុក្រឹត្យលេខ ១៧១ អនក្រ.បក ស្តីពី ការកំណត់តំបន់ឧទ្យានជាតិព្រះមុនីវង្ស " បូកគោ " និង ឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ " គីរីរម្យ " ៩៨៩៩

២៩-១២-២០១០ - អនុក្រឹត្យលេខ ១៧២ អនក្រ.បក ស្តីពី ការកែសម្រួលអត្រាអាករពិសេស និង អត្រាអាករនាំចេញលើទំនិញមួយចំនួន ៩៩០២

៣០-១២-២០១០ - អនុក្រឹត្យលេខ ១៧៣ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៧.៩៧២ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកឆ្លូង និង ស្រុកស្នួល ខេត្តក្រចេះ ៩៩០៨

៣០-១២-២០១០ - អនុក្រឹត្យលេខ ១៧៤ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៦.៩៩២ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកឆ្លូង និង ស្រុកស្នួល ខេត្តក្រចេះ ៩៩១១

៣០.១២.២០១០ -អនុក្រឹត្យលេខ ១៧៥ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៥.០៨៨ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកឆ្លូង ខេត្តក្រចេះ ៩៩១៤
៣០.១២.២០១០ -អនុក្រឹត្យលេខ ១៧៦ អនក្រ.បក ស្តីពី ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ៩៩១៧
៣០.១២.២០១០ -អនុក្រឹត្យលេខ ១៧៧ អនក្រ.បក ស្តីពី ការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារ ធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ៩៩១៩
៣០.១២.២០១០ -អនុក្រឹត្យលេខ ១៧៨ អនក្រ.បក ស្តីពី ការកែសម្រួលមាត្រា ២ ថ្មី នៃអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួល មាត្រា ២ ថ្មី នៃអនុក្រឹត្យ លេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល ៩៩២១
២៨.១២.២០១០ -អនុក្រឹត្យលេខ ១២៤៤ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៩៩២៤
២៨.១២.២០១០ -អនុក្រឹត្យលេខ ១២៤៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៩៩២៥
២៨.១២.២០១០ -អនុក្រឹត្យលេខ ១២៤៦ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៩៩២៦
២៨.១២.២០១០ -អនុក្រឹត្យលេខ ១២៤៧ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៩៩២៧
២៨.១២.២០១០ -អនុក្រឹត្យលេខ ១២៤៨ អនក្រ.តត ស្តីពី ការ ជូនមេដាយការងារ ៩៩២៨
២៨.១២.២០១០ -អនុក្រឹត្យលេខ ១២៤៩ អនក្រ.តត ស្តីពី ការ ជូនមេដាយការងារ ៩៩៣០
២៨.១២.២០១០ -អនុក្រឹត្យលេខ ១២៥០ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៩៩៣៦
២៨.១២.២០១០ -អនុក្រឹត្យលេខ ១២៥១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៣៨
២៨.១២.២០១០ -អនុក្រឹត្យលេខ ១២៥២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៣៩
២៨.១២.២០១០ -អនុក្រឹត្យលេខ ១២៥៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៤០
២៨.១២.២០១០ -អនុក្រឹត្យលេខ ១២៥៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៤១
២៨.១២.២០១០ -អនុក្រឹត្យលេខ ១២៥៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៤២
២៨.១២.២០១០ -អនុក្រឹត្យលេខ ១២៥៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៤៣
២៨.១២.២០១០ -អនុក្រឹត្យលេខ ១២៥៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៤៤
២៨.១២.២០១០ -អនុក្រឹត្យលេខ ១២៥៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៤៥
២៨.១២.២០១០ -អនុក្រឹត្យលេខ ១២៥៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៤៦
២៨.១២.២០១០ -អនុក្រឹត្យលេខ ១២៦០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៤៧
២៨.១២.២០១០ -អនុក្រឹត្យលេខ ១២៦១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៤៨
២៨.១២.២០១០ -អនុក្រឹត្យលេខ ១២៦២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៤៩

២៨.១២.២០១០ -អនុក្រឹត្យលេខ ១២៦៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៥០
២៨.១២.២០១០ -អនុក្រឹត្យលេខ ១២៦៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៥១

## ២-សេចក្តីសម្រេច

២៨.១២.២០១០ -សេចក្តីសម្រេចលេខ ៧៤ សសរ ស្តីពី ការបង្កើតគណៈបញ្ជាការ ការពារសន្តិសុខ គោលដៅ ទីស្តីការគណៈរដ្ឋមន្ត្រី និង ទីស្តីការនាយករដ្ឋមន្ត្រី ៩៩៥២

## III-ការខារបណ្ណាក្រសួខ

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៩.១២.២០១០ -ប្រកាសលេខ ១១៩៨ សហវ.ប្រក ស្តីពី ការកែសម្រួលអត្រាពន្ធគយលើមុខទំនិញនាំចូលមួយចំនួន ៩៩៥៥

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ & ក្រសួងយុត្តិធម៌

២៨.១២.២០១០ -ប្រកាសអន្តរក្រសួងលេខ ១១៩២ សហវ.កយ.ប្រក ស្តីពី ការកំណត់កម្រៃសេវារដ្ឋបាល នៃការផ្តល់ព្រឹត្តិបត្រថ្កោលទោស ៩៩៥៧

## ៣-ធនាគារជាតិ នៃ កម្ពុជា

២១.១២.២០១០ -ប្រកាសលេខ ធ ១២-០១០-២០៦ ប្រក ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម របស់បុគ្គលរាយការណ៍ ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារជាតិ នៃ កម្ពុជា ៩៩៦០

## ៤-ទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ & ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

១៣.១២.២០១០-ប្រកាសអន្តរក្រសួងលេខ ១៤០/៦០៦ ប្រក.កយ.កសក/១០ ស្តីពី ការផ្តល់នីតិសម្បទា ជាមន្ត្រីនគរបាលយុត្តិធម៌ ៩៩៩៦

## ៥-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២០.១២.២០១០ -ប្រកាសលេខ ១០១០ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វៀរដុង (ខេមបូឌា) លីមីធីត បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់, ស្រោមដៃ, កន្សែងបង់ក, មួក ១០០០៧
២០.១២.២០១០ -ប្រកាសលេខ ១០១១ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ៧ អេហ្វ ធីឌី ខូ អិលធីឌី បង្កើតរោងចក្រ ផលិតសសរគ្រឹះពីបេតុង, បង្គោលភ្លើងពីបេតុង ១០០១១

## ៦-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៥.៣.២០១០ -លិខិតបញ្ជាក់លេខ ១១៣៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ម៉ុង យុន គ្រុប ១០០១៥

*បញ្ជាក់: ព្រះរាជក្រម, ព្រះរាជក្រឹត្យ, អនុក្រឹត្យ... ដែលត្រូវចេញផ្សាយចុងឆ្នាំ ២០១០ នឹងបន្តចុះផ្សាយក្នុងរាជកិច្ច ដើមឆ្នាំ ២០១១ ។*

# ព្រះរាជក្រឹត្យ

នស/រកត/១២១០/៩៦២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

ចំពោះ

លោក យ៉ាំ សាឌីង

ដែលបានរួមចំណែកក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ
លើការអភិវឌ្ឍន៍មូលដ្ឋានក្នុងខេត្តកណ្តាល ទទួលបានជោគជ័យគួរជាទីមោទនៈ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

ពរឈ. ១០១២. ៩៧៩

នរោត្តម សីហមុនី

លេខ:៨៦០ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១០

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុំ ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១២១០/៩៦៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **ជឹម សារឿន** អត្តលេខ ០១៨៩ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៤ល.១០១២.៩៤០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១០

លេខ:៨៥៨ ច.ល

បានឃើញដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១០

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១២១០/៩៦៤

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ជាកិត្តិយសបច្ឆាមរណៈ

ចំពោះ

សពនាយទាហាន នៃកងយោធពលខេមរភូមិន្ទ ចំនួន០៨រូប មានគុណបំណាច់និងស្នាដៃល្អ
ក្នុងការធ្វើពលីកម្មគ្រប់បែបយ៉ាង ដើម្បីការពារជាតិមាតុភូមិ និងប្រជារាស្ត្រ កន្លងមក

នូវ

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

| | | | | |
|---|---|---|---|---|
| ១- | ឧត្តមសេនីយ៍ឯក | ប្រូចថ ម៉ុនថុល | អត្តលេខ | ០០០១៧៨ |
| ២- | ឧត្តមសេនីយ៍ឯក | អន កំសត់ | អត្តលេខ | ០០០៦៣៦ |
| ៣- | ឧត្តមសេនីយ៍ទោ | គៀក សារី | អត្តលេខ | ០០០៧៥៥ |
| ៤- | ឧត្តមសេនីយ៍ត្រី | នុត ផូ | អត្តលេខ | ០០២០៩៨ |
| ៥- | ឧត្តមសេនីយ៍ត្រី | គៀត ម៉ុនហុង | អត្តលេខ | ០០០៣៩២ |

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**

| | | | | |
|---|---|---|---|---|
| ១- | ឧត្តមសេនីយ៍ត្រី | ឡាំ ច័ន្ទវណ្ណដា | អត្តលេខ | ០០២២៣១ |
| ២- | វរសេនីយ៍ឯក | សួស ចំរើន | អត្តលេខ | ០០៤២១៨ |
| ៣- | វរសេនីយ៍ឯក | ជឹម បូរ៉ា | អត្តលេខ | ០២២៣០១ |

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល. ១០១២. ៩៤១

លេខ:៤៥៧ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យុន ជិនកេន

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១០*

# ព្រះរាជក្រឹត្យ

នស/រកត/១២១០/៩៦៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

**ឯកឧត្តម លោកជំទាវ នាយនគរបាលជាតិ នាយទាហាន មន្ត្រីរាជការ និងសប្បុរសជន ដែលបានបរិច្ចាគធនធាន ចូលរួមកសាងហេដ្ឋារចនា សម្ព័ន្ធ សង្គមជាតិ និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ នៅស្រុកល្វាឯម ខេត្តកណ្តាល**

**នូវ**

**ក. គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេនា :**

១-លោកជំទាវ **ជួន គីម**

២-លោកឧត្តមសេនីយ៍ទោ **គ្រាក់ ភារណារ៉ា** **អត្តលេខ០១៦៥**

៣-លោកឧត្តមសេនីយ៍ត្រី **ម៉ុន ចាន់ធន្ន** **អត្តលេខ០១០១៦**

**ខ. គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធិ :**

១-លោកឧត្តមសេនីយ៍ត្រី **ម៉ាត់ ណារី** **អត្តលេខ០១៥៣**

២-លោកឧត្តមសេនីយ៍ត្រី **សួន គីមស្រ៊ុន** **អត្តលេខ០១៣៣**

៣-លោកឧត្តមសេនីយ៍ត្រី **យន់ ខេង** **អត្តលេខ០១០៤៩**

៤-លោកវរសេនីយ៍ឯក **ង៉ាង ពៅ** **អត្តលេខ១២៦៤៤**

**គ. គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់មហាសេរីវឌ្ឍន៍ :**

១-ឯកឧត្តម **ឯម សំអាន**

២-លោកឧត្តមសេនីយ៍ឯក **អៅ គីមឈួន** **អត្តលេខ០០៧៤**

៣-លោកឧត្តមសេនីយ៍ត្រី **ឯម ចិចិត្រ** **អត្តលេខ០៤៤៤៥**

៤-លោកឧត្តមសេនីយ៍ត្រី **ជុំ ឈេង** **អត្តលេខ០៦២២១**

៥-លោកស្រី **ឯម សុជាតិ**

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ឃ. គ្រឿងឥស្សរិយយស មុនីសារាភណ្ឌ ថ្នាក់មហាសេរីវឌ្ឍន៍ :

១-លោកវរសេនីយ៍ទោ សំ ជាវ៉ា អត្តលេខ០៧ddd
២-លោកវរសេនីយ៍ឯក ឈី គុងហួរ អត្តលេខ១៦២០៤០
៣-លោកវរសេនីយ៍ឯក សៀង សេន អត្តលេខ០១៨១៣
៤-លោក សេ គិរុណា
៥-លោក ហ៊ុង ឈី

ង. គ្រឿងឥស្សរិយយស មុនីសារាភណ្ឌ ថ្នាក់មហាសេនា :

១-ឯកឧត្តម ធីង ចាន់ថូ
២-លោកឧត្តមសេនីយ៍ត្រី ចាំ សាច័ន អត្តលេខ២០១៧៦
៣-លោក កង សោផាន
៤-លោកស្រី អ៊ិន សុភារី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣៧ល.១០១២.៩៩២

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១០ លេខ: ៨៥៥ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១២១០/៩៦៧

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៩/៩៤៣ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៩ ស្តីពីការកែសម្រួល និងការធ្វើនិយតកាពការបង្កើតគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១២០៩/១១៨១ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងការកែសម្រួលឋានៈរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំងឯកឧត្តម **តែ ណាវុធ** ជាអគ្គលេខាធិការគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ជំនួសឯកឧត្តម **ពេជ ឌុន** ដែលត្រូវបានចាត់ឲ្យទទួលភារកិច្ចថ្មី។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣.រ.ល. ១០១២.៩៩៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០

**លេខ: ៨៥៦ ច.ល**

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១០

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ស៊ុន ជិនកេន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៣៤១ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់ឧទ្យានជាតិព្រះមុនីវង្ស«បូកគោ»

## និងឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ«គីរីរម្យ»

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី តំបន់ការពារធម្មជាតិ

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ

-បានឃើញអនុក្រឹត្យលេខ ៥៧អនក្រ/បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## ស ម្រេ ច

**មាត្រា១.-**

ត្រូវបានកែសម្រួល និងកំណត់ផ្ទៃដីឧទ្យានជាតិព្រះមុនីវង្ស «បូកគោ» ទំហំ១៥៩.៩៥៨(មួយរយហាសិបបួនពាន់ បួនរយហាសិបប្រាំបី)ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកំពត ខេត្តព្រះសីហនុ និងខេត្តកំពង់ស្ពឺ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១ កំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកាដូចខាងក្រោម៖

| Nº | X | Y | Nº | X | Y | Nº | X | Y |
|---|---|---|---|---|---|---|---|---|
| A | 402810 | 1168653 | J | 383146 | 1220836 | S | 406537 | 1231627 |
| B | 400650 | 1168148 | K | 390001 | 1228888 | T | 408004 | 1225468 |
| C | 395184 | 1171052 | L | 390000 | 1231510 | U | 408004 | 1215883 |
| D | 387286 | 1171587 | M | 392423 | 1231605 | V | 403996 | 1210001 |
| E | 384045 | 1174392 | N | 394181 | 1227998 | W | 404999 | 1197997 |
| F | 378487 | 1187086 | O | 396796 | 1232460 | X | 408869 | 1180152 |
| G | 377158 | 1195536 | P | 395566 | 1236924 | Y | 404933 | 1173146 |
| H | 379176 | 1205847 | Q | 402616 | 1238796 | Z | 405501 | 1170055 |
| I | 384777 | 1209233 | R | 404316 | 1232325 | | | |

**មាត្រា២.-**

ត្រូវបានកែសម្រួល និងកំណត់ផ្ទៃដីឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ«គីរីរម្យ»ទំហំ៣៥.២៣២(សាមសិបប្រាំពាន់ ពីររយសាមសិបពីរ)ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ២ កំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកាដូចខាងក្រោម៖

| Nº | X | Y | Nº | X | Y |
|---|---|---|---|---|---|
| A | 402619 | 1238913 | G | 396523 | 1261014 |
| B | 395542 | 1237006 | H | 402131 | 1260618 |
| C | 393585 | 1238477 | I | 405891 | 1257039 |
| D | 388012 | 1245801 | J | 405620 | 1249874 |
| E | 390237 | 1260167 | K | 404103 | 1244483 |
| F | 392695 | 1261817 | | | |

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ខេត្តកំពត និងខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៧២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១. នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០១.នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២១ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការកែសម្រួល អត្រាពន្ធគយ និងអាករលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ និងអាករពិសេសលើទំនិញ និងសេវាមួយចំនួន និងអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន

- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន
- យោងតាមសំណូមពរការងារចាំបាច់

## សម្រេច

**មាត្រា ១.-**

ត្រូវបានកែសម្រួលអត្រាអាករពិសេសលើមុខទំនិញនាំចូលចំនួន ១៩ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមាន រួមមាន ៖

- តម្លើងអត្រាអាករពិសេសពី ១០% ទៅ ២០% ចំនួន ១៣ បន្ទាត់ពន្ធ ចំពោះបណ្តាមុខទំនិញនៃទីតាំងរងលេខ ៨៧០២.១០.១១ ៨៧០២.១០.១២ ៨៧០២.១០.១៣ ៨៧០២.១០.១៩ ៨៧០២.១០.២១ ៨៧០២.១០.២២ ៨៧០២.១០.២៣ ៨៧០២.១០.២៤ ៨៧០២.៩០.១១ ៨៧០២.៩០.១៩ ៨៧០២.៩០.៩១ ៨៧០២.៩០.៩៩ និង ៨៧១៦.៩០.៩៩ ។
- បន្ថយអត្រាអាករពិសេសពី ៣៣,៣៣% មក ១០% ចំនួន ០៦ បន្ទាត់ពន្ធ ចំពោះបណ្តាមុខទំនិញនៃទីតាំងរងលេខ ២៧១០.១១.១១ ២៧១០.១១.១២ ២៧១០.១១.១៣ ២៧១០.១១.១៤ ២៧១០.១១.១៥ និង ២៧១០.១១.១៦ ។

**មាត្រា ២.-**

ត្រូវបានកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញចំនួន ២៧ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមាន រួមមាន ៖

- តម្លើងអត្រាអាករនាំចេញពី ១០% ទៅ ២០% លើមុខទំនិញចំនួន ២០ បន្ទាត់ពន្ធ ចំពោះបណ្តាមុខទំនិញនៃទីតាំងរងលេខ ២៥១៥.១១.០០ ២៥១៥.២០.០០ ២៥១៦.១១.០០២៥១៦.២០.០០ ២៥១៦.៩០.០០ ២៥១៧.១០.០០ ២៥១៧.២០.០០ ២៥១៧.៤១.០០ ២៥១៧.៤៩.០០ ៧២០៤.១០.០០ ៧២០៤.២១.០០ ៧២០៤.២៩.០០ ៧២០៤.៣០.០០ ៧២០៤.៤១.០០ ៧២០៤.៥០.០០ ៧៤០៤.០០.០០ ៧៦០២.០០.០០ ៧៨០២.០០.០០ ៧៩០២.០០.០០ និង ៨០០២.០០.០០ ។
- បន្ថយអត្រាអាករនាំចេញពី ១០% មក ០% លើមុខទំនិញចំនួន ០៧ បន្ទាត់ពន្ធ ចំពោះបណ្តាមុខទំនិញនៃទីតាំងរងលេខ ២៥២៣.១០.១០ ២៥២៣.១០.៩០ ២៥២៣.២១.០០ ២៥២៣.២៩.១០ ២៥២៣.២៩.៩០ ២៥២៣.៣០.០០ និង ២៥២៣.៩០.០០ ។

**មាត្រា ៣.-**

ត្រូវបានកំណត់ការប្រមូលអាករនាំចេញតាមរបៀប "ពន្ធគិតតាមឯកតា" លើមុខទំនិញជ័រកៅស៊ូចំនួន ៥៦ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមាន ដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ តាមរូបភាពដូចខាងក្រោម ៖

- ជាប់អាករនាំចេញ ៥០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញទាបជាង ២០០០ ដុល្លារអាមេរិកក្នុង ១ តោន ។
- ជាប់អាករនាំចេញ ១៥០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ២០០០ តែទាបជាង ៣០០០ ដុល្លារអាមេរិកក្នុង ១ តោន ។
- ជាប់អាករនាំចេញ ២០០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ៣០០០ តែទាបជាង ៤០០០ ដុល្លារអាមេរិកក្នុង ១ តោន ។

- ជាប់អាករនាំចេញ ៣០០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ៤០០០ ដុល្លារអាមេរិកឡើងក្នុង ១ តោន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកចាត់ចែងអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១១ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
ដើម្បីចុះហត្ថលេខា

**គាត ឈន់**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់សាលាខេត្ត និងសាលារាជធានី
- ដូចមាត្រា ៥
- រាជកិច្ច

## ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ១៧៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០១០
## ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន

| Head. | Tariff Code | បរិយាយមុខទំនិញ | Description of Goods |
|---|---|---|---|
| 40.01 | | កៅស៊ូធម្មជាតិ ជ័របាលាតា ជ័រ guttapercha ជ័រ guayule ជ័រលុត និងជ័រធម្មជាតិ ស្រដៀងគ្នាក្នុងទំរង់ដើម ឬជាផ្ទាំក ជាសន្លឹក ឬជាបន្ទះ ។ | **Natural rubber, balata, gutta-percha, guayule, chicle and similar natural gums, in primary forms or in plates, sheets or strip.** |
| | 4001.10.11 | - - - កំហាប់សង់ទ្រីហ្វុយ | - - - Centrifuge concentrate |
| | 4001.10.19 | - - - ផ្សេងទៀត | - - - Other |
| | 4001.10.21 | - - - កំហាប់សង់ទ្រីហ្វុយ | - - - Centrifuge concentrate |
| | 4001.10.29 | - - - ផ្សេងទៀត | - - - Other |
| | 4001.21.10 | - - - គុណភាព Rss1 | - - - RSS Grade 1 |
| | 4001.21.20 | - - - គុណភាព Rss2 | - - - RSS Grade 2 |
| | 4001.21.30 | - - - គុណភាព Rss3 | - - - RSS Grade 3 |
| | 4001.21.40 | - - - គុណភាព Rss4 | - - - RSS Grade 4 |
| | 4001.21.50 | - - - គុណភាព Rss5 | - - - RSS Grade 5 |
| | 4001.21.90 | - - - ផ្សេងទៀត | - - - Other |
| | 4001.22.10 | - - - កៅស៊ូស្តង់ដាឥណ្ឌូណេស៊ី | - - - Standard Indonosian rubber SIR 3 CV |
| | 4001.22.20 | - - - កៅស៊ូស្តង់ដាឥណ្ឌូណេស៊ី ផ្សេងទៀត | - - - Other Standard Indonesian rubber |
| | 4001.22.30 | - - - កៅស៊ូស្តង់ដា ម៉ាឡេស៊ី | - - - Standard Malaysian rubber |
| | 4001.22.40 | - - - កៅស៊ូស្តង់ដា សិង្ហបុរី | - - - Specified Singapore rubber |
| | 4001.22.50 | - - - កៅស៊ូស្តង់ដា ថៃ | - - - Thai tested rubber |
| | 4001.22.90 | - - - ផ្សេងទៀត | - - - Other |
| | 4001.29.10 | - - - សន្លឹកចំអិនដោយខ្យល់ | - - - Air-dried sheet |
| | 4001.29.20 | - - - ជ័រគ្រែបរាវ (តាលិច) | - - - Latex crepe |
| | 4001.29.30 | - - - ជ័រគ្រែបបាត | - - - Sole crepe |
| | 4001.29.40 | - - - ជ័រគ្រែបច្នៃឡើងវិញរាប់បញ្ចូលទាំងជ័រគ្រែប | - - - Remilled crepe, including flat bark crepe |
| | 4001.29.50 | - - - ជ័រគ្រែបផ្សេងទៀត | - - - Other crepe |
| | 4001.29.60 | - - - កៅស៊ូកែច្នៃគុណភាព | - - - Superior processing rubber |
| | 4001.29.70 | - - - កំណកពពុះកៅស៊ូខាងលើ | - - - Skim rubber |
| | 4001.29.80 | - - - កំទេចសំណល់កៅស៊ូ(ដើមឈើ ដី ឬ ផ្សែង) និងខាប់ឡាំ (cup lump) | - - - Scrap (tree, earth or [illegible] and cup lump |
| | 4001.29.90 | - - - ផ្សេងទៀត | - - - Other |
| | 4001.30.11 | - - - ក្នុងទម្រង់ដើម | - - - In primary form |

| | | | |
|---|---|---|---|
| | 4001.30.19 | - - - ផ្សេងទៀត | - - - Other |
| | 4001.30.91 | - - - ក្នុងទម្រង់ដើម | - - - In primary form |
| | 4001.30.99 | - - - ផ្សេងទៀត | - - - Other |
| **40.02** | | កៅស៊ូសំយោគ និងកៅស៊ូចេញមកពីប្រេងផ្សេងៗក្នុងទំរង់ដើម ឬផ្ទាំង ជាសន្លឹក ឬជាល្បាយផលិតផលនៃទីតាំងលេខ ៤០.០១ ជាមួយផលិតផលនៃទីតាំងនេះ ក្នុងទម្រង់ដើម ឬជាផ្ទាំង ជាស្លឹក ឬជាបង់ ។ | **Synthetic rubber and factice derived from oils, in primary forms or in plates, sheets or strip; mixtures of any product of heading No. 40.01 with any product of this heading, in primary forms or in plates, sheets or strip.** |
| | 4002.11.00 | - - ជ័រកៅស៊ូរាវ | - - Latex |
| | 4002.19.00 | - - ផ្សេងទៀត | - - Other |
| | 4002.20.00 | - កៅស៊ូ ប៊ុយតាឌីយ៉ែន ( BR ) | - Butadiene rubber (BR) |
| | 4002.31.00 | - - កៅស៊ូអ៊ីសូប៊ុយតែន- អ៊ីសូប្រ៉ែន (ប៊ុយទីល) ( IIR ) | - - Isobutene-isoprene (butyl) rubber (IIR) |
| | 4002.39.00 | - - ផ្សេងទៀត | - - Other |
| | 4002.41.00 | - - ជ័រកៅស៊ូរាវ | - - Latex |
| | 4002.49.00 | - - ផ្សេងទៀត | - - Other |
| | 4002.51.00 | - - ជ័រកៅស៊ូរាវ | - - Latex |
| | 4002.59.00 | - - ផ្សេងទៀត | - - Other |
| | 4002.60.10 | - - ក្នុងទម្រង់បឋម | - - In primary forms |
| | 4002.60.90 | - - ផ្សេងទៀត | - - Other |
| | 4002.70.00 | - កៅស៊ូអេទីឡែន - ប្រូពីឡែន- មិនលាយជាមួយឌីយ៉ែន (EPDM ) | - Ethylene-propylene-non-conjugated diene rubber (EPDM) |
| | 4002.80.10 | - - ល្បាយកៅស៊ូធម្មជាតិជាមួយកៅស៊ូសំយោគទឹករាវ | - - Mixture of natural rubber latex with synthetic rubber latex |
| | 4002.80.90 | - - ផ្សេងទៀត | - - Other |
| | 4002.91.10 | - - - ជ័រកៅស៊ូរាវ | - - - Latex |
| | 4002.91.90 | - - - ផ្សេងទៀត | - - - Other |
| | 4002.99.10 | - - - កៅស៊ូធម្មជាតិផ្សាំ នៃប៉ូលី(មេទីល- មេតាគ្រីលាត) | - - - Of poly(methyl-methacrylate)graft natural rubber |
| | 4002.99.90 | - - - ផ្សេងទៀត | - - - Other |
| **40.03** | 4003.00.00 | កៅស៊ូច្នៃឡើងវិញក្នុងទំរង់ដើម ឬជាផ្ទាំង ជាសន្លឹក ឬជាបង់ | **Reclaimed rubber in primary forms or in plates, sheets or strip.** |
| **40.04** | 4004.00.00 | សំណល់ កំទេចកៅស៊ូ (ក្រៅពីកៅស៊ូរឹង) ម្សៅ និងគ្រាប់បានមកនោះ | **Waste, parings and scrap of rubber (other than hard rubber) and powders and granules obtained therefrom.** |
| **40.05** | | កៅស៊ូល្បាយមិនទាន់លាយស្ពាន់ធ័រ ក្នុងទំរង់ដើមជាផ្ទាំង ជាសន្លឹក ឬជាបង់ | **Compounded rubber, unvulcanised, in primary forms or in plates, sheets or strip.** |
| | 4005.10.00 | - លាយជាមួយកាបោនប្លែក ឬស៊ីលីស | - Compounded with carbon black or silica |
| | 4005.20.00 | - ល្បាយ ល្បាយមិនលាយក្រៅពីល្បាយនៃទីតាំងរងលេខ ៤០.០៥.១០ | - Solutions, dispersions other than those of subheading No. 4005.10 |

| | | | |
|---|---|---|---|
| | 4005.91.00 | - - ផ្ទាក សន្លឹក បង់ធី | - - Plates, sheets and strip |
| | 4005.99.00 | - - ផ្សេងទៀត | - - Other |
| **40.06** | | ទំរង់ផ្សេងទៀត (ឧទាហរណ៍ដើមមូលវែង ទិប និងប្រូហ្វ៊ីឡេ) និងវត្ថុ (ឧទា. ថាសកង់) ធ្វើពីកៅស៊ូមិនទាន់លាយស្ពាន់ធ័រ ។ | **Other forms (for example, rods, tubes and profile shapes) and articles (for example, discs and rings), of unvulcanised rubber.** |
| | 4006.10.00 | - ប្រូហ្វ៊ីឡេសំរាប់ចាក់កង់រថយន្តឡើងវិញ | - "Camel-back" strips for retreading rubber tyres |
| | 4006.90.00 | - ផ្សេងទៀត | - Other |
| **40.07** | 4007.00.00 | សសៃ និងខ្សែរធ្វើពីកៅស៊ូលាយស្ពាន់ធ័រ | **Vulcanised rubber thread and cord.** |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៧៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៧.៩៧២ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកឆ្លូង និងស្រុកស្នួល ខេត្តក្រចេះ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា១: –**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៧.៩៧២ ហិកតា ស្ថិតនៅក្នុងភូមិសាស្រ្ត ឃុំដីវីផុង ឃុំកំពង់ដំរី ស្រុកឆ្លូង និងឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ ដើម្បីធ្វើការវិនិយោគដាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកាលេខ២២៩៤ ចណ.ក្រច ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០ របស់សាលាខេត្តក្រចេះ ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា២: –**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍ របស់រាជរដ្ឋាភិបាល ។

**មាត្រា៣: –**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤ –**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

ផែនទីៈ ចំណុចគោលព្រំដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ជុងនៀង (ខេមបូឌា) រ៉ាប់ប៊ើរ ឌីវេឡុបមេន ខមភេនី លីមីធីត(ជាខេមរុខ)

ស្ថិតនៅក្នុង ឃុំដំរីផុង ឃុំកំពង់ដំរី ស្រុកឆ្លូង និងឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ




បានឃើញ និង ឯកភាព

សូមគោរពជូន ឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និង សម្រេច

ស្នួល ថ្ងៃទី......ខែ.......ឆ្នាំ ២០១០

អភិបាលស្រុក

ស៊ុម.សារិត

បានឃើញ និង ឯកភាព

សូមគោរពជូន ឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និង សម្រេច

ស្នួល ថ្ងៃទី......ខែ.......ឆ្នាំ ២០១០

អភិបាលស្រុក

បានឃើញ និង ឯកភាព

សូមគោរពជូន ឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និង សម្រេច

ក្រចេះ ថ្ងៃទី......ខែ.......ឆ្នាំ ២០១០

ប្រធានមន្ទីរកសិកម្មខេត្ត

គួយ. ហួត

បានឃើញ និង ឯកភាព

សូមគោរពជូន ឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និង សម្រេច

ក្រចេះ ថ្ងៃទី......ខែ.......ឆ្នាំ ២០១០

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត

ម៉ៅ.សុផាត

បានឃើញ និង ឯកភាព

គោរពជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម

រុក្ខាប្រមាញ់ និង នេសាទ មេត្តាពិនិត្យ និង សម្រេច

ក្រចេះ ថ្ងៃទី......ខែ.......ឆ្នាំ ២០១០

អភិបាលខេត្ត

ខាវ៉ាន់.គៀវ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៦.៩៩២ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកឆ្លូង និងស្រុកស្នួល ខេត្តក្រចេះ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា១: –**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៦.៩៩២ ហិកតា ស្ថិតនៅក្នុងភូមិសាស្រ្ត ឃុំព្រៃកសាមាន់ ឃុំជីវផុង ស្រុកឆ្លូង និងឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ ដើម្បីធ្វើការវិនិយោគដាំកៅស៊ូ ដូចមានក្នុងផែនទីនិងនិយាមកាលេខ២២៩២ ចណ.ក្រច ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០ របស់សាលាខេត្តក្រចេះ ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា២: –**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍ របស់រាជរដ្ឋាភិបាល ។

**មាត្រា៣: –**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤ –**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ៨ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល :</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

ផែនទីៈ ចំណុចគោលព្រំដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ជួនឡៅ-ក្រចេះ រ៉ាប់ប៊ើរ ឌីវេឡុបមេន ខមផេនី លីមីតធីត(ដាក្រាខ្)

ស្ថិតនៅក្នុង ឃុំព្រែកសាម៉ាន់ ឃុំជីផុង ស្រុកឆ្លូង និងឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ




សញ្ញាសំគាល់

- ចំណុចគោលព្រំដី
- ចំណុចព្រំដីសម្បទានសេដ្ឋកិច្ចកាសូទីម
- ព្រំប្រទល់ឃុំ
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ខេត្ត
- ផ្លូវទឹក
- ខ្សែរយៈកំពស់
- ផ្លូវជាតិ និង ផ្លូវលើកថ្មី
- ផ្លូវរទេះ
- ផ្លូវដើរ

ព្រៃឈើ ៧០០៦-៨០០០ ហ.ត

- ព្រៃស្រោង- ៥៧០៥ ហ.ត
- ព្រៃពាក់កណ្តាលស្រោង- ២០០៩ ហ.ត
- ព្រៃល្បោះ- ៦៥ ហ.ត
- ដីគ្មានគម្របព្រៃ- ២៦១ ហ.ត

- ព្រំប្រទល់ដីស្នើសុំ -៨០០០ ហ.ត
- ដីសម្បទានសេដ្ឋកិច្ច កាសូទីម -៦៨៧ហ.ត
- តំបន់ត្រូវកាត់ផ្លូវទឹកក្រោម ៧៥០ម - ៣៨៥.៥ហ.ត

ផ្ទៃដីកាត់ផ្ទុប្រជាពលរដ្ឋដែលនៅរាយប៉ាយ-៣៨៥.៥ហ.ត

ផ្ទៃដីនៅសល់សរុប - ៦៩៥៦ ហ.ត

N W E S

Coordinate System
Horizontal Datum : Indian 1960
Zone : 48
Projection : UTM
Spheroid : Everest

Scale1:60,000
0 600 1,200 M

បានឃើញ និង ឯកភាព
សូមគោរពជូន ឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និង សម្រេច
ថ្ងៃ........ខែ........ឆ្នាំ ២០១០
មេឃុំព្រែកសាម៉ាន់
សូម_សារិត

បានឃើញ និង ឯកភាព
សូមគោរពជូន ឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និង សម្រេច
ថ្ងៃ........ខែ........ឆ្នាំ ២០១០
មេឃុំជីផុង
អ៊ឹង_សាតុំ

បានឃើញ និង ឯកភាព
សូមគោរពជូន ឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និង សម្រេច
ថ្ងៃ........ខែ........ឆ្នាំ ២០១០
ប្រធានមន្ទីរកសិកម្មខេត្ត
គុយ. ហួត

បានឃើញ និង ឯកភាព
សូមគោរពជូន ឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និង សម្រេច
ថ្ងៃ........ខែ........ឆ្នាំ ២០១០
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត
ហ៊ាន់_សុផាត

បានឃើញ និង ឯកភាព
គោរពជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និង នេសាទ មេត្តាពិនិត្យ និង សម្រេច
ក្រចេះ ថ្ងៃ........ខែ........ឆ្នាំ ២០១០
អភិបាលខេត្ត
ខាំ_គឿន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៧៥ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩.០៨៨ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកឆ្លូង ខេត្តក្រចេះ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា១:-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៥.០៨៨ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំដីផុង និងឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ ដើម្បីធ្វើការវិនិយោគដាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកាលេខ២២៩៣ ចណ.ក្រច ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០ របស់សាលាខេត្តក្រចេះ ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា២:-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍ របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ


N
W E
S
Coordinate System
Horizontal Datum : Indian 1960
Zone : 48
Projection : UTM
Spheroid : Everest
Scale 1:60,000

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៧៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ ប្រើប្រាស់ដោយចីរភាព
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល ។

# សម្រេច

**មាត្រា១៖**

ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃភ្នំសំកុស លើផ្ទៃដីទំហំ១.៩៥០ហិកតា (**មួយពាន់ ប្រាំបួនរយ ហាសិបហិកតា**) ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រ **ស្រុកវាលវែង ខេត្តពោធិសាត់** សម្រាប់ផ្តល់ជូនក្រុមហ៊ុន **អិម ឌី អេស អាហ៊រណេ នីហ៊រណេ** ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម (ដំណាំកៅស៊ូ) ដែលមានទីតាំង និងនិយាមកាដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ១៤៩០ សជណ.កស ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ២០១០ជាឧបសម្ព័ន្ធ។

**មាត្រា២៖**

ត្រូវបាននិរាករណ៍អនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព។

**មាត្រា៣៖**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តពោធិសាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ ប្រើប្រាស់ដោយចីរភាព
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល ។

## សម្រេច

**មាត្រា១៖**

ត្រូវធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១០ ក្នុងមាត្រា៣ នៅបន្ទាត់ទី៣ ត្រូវបានកែសម្រួលពី «.....គណៈអភិបាលខេត្តក្រចេះ » មកជាៈ «.... គណៈអភិបាលខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ» វិញ ដែលមានខ្លឹមសារ នៃមាត្រា៣ ដូចខាងក្រោមៈ

«រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ **និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ** ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ»។

**មាត្រា២៖**

ខ្លឹមសារនៃមាត្រាដទៃផ្សេងទៀត របស់អនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព នៅតែមានសុពលភាពជាគតិយុត្តិដដែល។

**មាត្រា៣៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៧៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលមាត្រា ២ថ្មី នៃអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលមាត្រា ២ នៃអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការសម្រួលមាត្រា ២ នៃអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- តាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល

## សម្រេច

**មាត្រា មួយ.-**

ត្រូវបានកែសម្រួលមាត្រា ២ថ្មី នៃអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការសម្រួលមាត្រា ២ នៃអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដូចតទៅ ៖

**មាត្រា ២ថ្មី(ពីរ)..**

សមាសភាពនៃគណៈកម្មាធិការជាតិបណ្ដុះបណ្ដាល មានដូចខាងក្រោម ៖

| | |
|---|---|
| ១- ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- តំណាងក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣- តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៤- តំណាងក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៥- ប្រធានសភាមុខរបរ និងមីក្រូសហគ្រាស | អនុប្រធាន |
| ៦- តំណាងនិយោជក | អនុប្រធាន |
| ៧- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨- តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩- តំណាងក្រសួងសុខាភិបាល | សមាជិក |
| ១០- តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១១- តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១២- តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៣- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៤- តំណាងក្រសួងទេសចរណ៍ | សមាជិក |
| ១៥- តំណាងក្រសួងកិច្ចការនារី | សមាជិក |
| ១៦- តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៧- តំណាងក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៨- តំណាងក្រសួងផែនការ | សមាជិក |
| ១៩- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២០- តំណាងក្រសួងបរិស្ថាន | សមាជិក |
| ២១- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២២- ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ | សមាជិក |
| ២៣- តំណាង ៤រូប របស់និយោជក | សមាជិក |
| ២៤- តំណាង ១រូប របស់សភាពាណិជ្ជកម្ម | សមាជិក |
| ២៥- តំណាង ២រូប របស់នាយោជិត | សមាជិក |
| ២៦- តំណាង ៣រូប ជាអ្នកផ្ដល់ការបណ្ដុះបណ្ដាល | សមាជិក |
| ២៧- តំណាងក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | នាយកប្រតិបត្តិ។ |

គណៈកម្មាធិការជាតិអាចអញ្ជើញតំណាង ៣រូប របស់អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ចូលរួមបាន។

គណៈកម្មាធិការជាតិនេះ មានអគ្គនាយកដ្ឋានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍។

**មាត្រា ពីរ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥..**

